ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ:៤២
ចុះថ្ងៃទី១៨-០១-២០១៣
សាលដីកា
លេខ: ៦៣ "ក្រ VI ញ"
ចុះថ្ងៃទី២៩-៨-២០១៣

# គោរពនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើ តាមក្រឹត្យលេខ: ០៦ ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍នា ថ្ងៃទី២៩-សីហា-២០១៣ ម៉ោង៨:០០នាទីព្រឹក ដោយមានសមាសភាពដូចតទៅ:

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធាន
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted] ជាព្រះរាជអាជ្ញា

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងក្តីព្រហ្មទណ្ឌលេខ:៤២ ចុះថ្ងៃទី១៨-០១-២០១៣រវាង:

**-ជនជាប់ចោទ:**

១-ឈ្មោះ [redacted]គា ហៅ [redacted] សាព៉ា ភេទប្រុស អាយុ៤៩ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិ ពាមកោះស្នា ឃុំពាមកោះស្នា ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម មុខរបរយោធា មុនពេលចាប់ខ្លួនមានទីលំនៅស្នាក់[redacted]ស្រុកស្នួល ខេត្តក្រចេះ ឪពុកឈ្មោះ[redacted]) ម្តាយឈ្មោះ [redacted](រ) ប្រពន្ធឈ្មោះ ពឹម បូ (លែងលះ) មានកូន០៥នាក់ (ឃុំខ្លួនថ្ងៃទី១០-៤-២០១១)។

ជាប់ចោទពីបទ: ប៉ុនប៉ងឃាតកម្ម បទកាន់កាប់អាវុធដោយគ្មានលិខិតអនុញ្ញាត បទធ្វើសន្និធិផលអនុផលព្រៃឈើ និងបទប្រមូលផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ប្រព្រឹត្តនៅភូមិសំបូរ ឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ កាលពីថ្ងៃទី០៨-៤-២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា២៧, មាត្រា១៩៩ និងមាត្រា៤៩០ នៃក្រមព្រហ្មទណ្ឌ, មាត្រា៩៦-១-៣ និងមាត្រា៩៨-២-៥ នៃច្បាប់ស្តីពីព្រៃឈើ ។

២-ឈ្មោះ [redacted] រិទ្ធិ ភេទប្រុស អាយុ២៨ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតភូមិស្រែស្តៅ ឃុំទួលសុភី ស្រុកអូររាំងឪ ខេត្តកំពង់ចាម ឪពុកឈ្មោះ [redacted]) ម្តាយឈ្មោះ [redacted]) (ឃុំខ្លួនថ្ងៃទី១០-៤-២០១១)។

ជាប់ចោទពីបទ: ប្រមូលផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ប្រព្រឹត្តនៅភូមិសំបូរ ឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ កាលពីថ្ងៃទី០៨-៤-២០១១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៩៨ និងមាត្រា១៩៩-១-៥ នៃច្បាប់ស្តីពីព្រៃឈើ ។

## ឯរឿងហេតុមានដូចតទៅ

កាលពីថ្ងៃទី០៨-៤-២០១១ សមត្ថកិច្ចចំរុះបានចុះធ្វើការត្រួតពិនិត្យលំនៅដ្ឋានឈ្មោះ [redacted]គា ឃើញមានលាក់ទុកឈើក្នុងរថយន្តនៅក្រោមផ្ទះ ក្រោយផ្ទះ ចំហៀងផ្ទះ ហើយត្រូវឈ្មោះ [redacted]គា ទាញយកអាវុធAK និងអាវុធខ្លីធុនK59 បាញ់ទៅលើសមត្ថកិច្ចចំនួន០៩គ្រាប់ (AKបាញ់ចំនួន០៥គ្រាប់ និងអាវុធខ្លី K59 បាញ់ចំនួន០៤គ្រាប់) ធ្វើឲ្យសមត្ថកិច្ចលំបាកក្នុងការចាត់ការ។ ពេលដែលបាញ់រួចហើយឈ្មោះថៃ គាបានយកអាវុធAK ទៅលាក់ទុកក្នុងរថយន្តកាមរីឆ្លាម ដែលបានស្តុកទុកឈើក្រញូង។ សមត្ថកិច្ចកងរាជអាវុធហត្ថ បានធ្វើការឃាត់ខ្លួនឈ្មោះ [redacted] គា និងឈ្មោះ [redacted] រិទ្ធិ ចាត់ចែងបទល្មើសព្រៃឈើទៅតាមនីតិវិធី ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ: ២៣ "ច" ចុះថ្ងៃទី១៧-៩-២០១២ របស់សាលាដំបូងខេត្តក្រចេះ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចខាងក្រោម ៖

១.កែប្រែបទប្បញត្តិចោទប្រកាន់ លើឈ្មោ[redacted]គា ហៅ [redacted] សាព៉ា ពីបទ ប៉ុងប៉ងឃាតកម្ម មកបទគំរាមកំហែងរាំងស្ទះដល់ការបំពេញភារកិច្ច និង កិច្ចប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលព្រៃឈើ ប្រព្រឹត្ត នៅភូមិសំបូរ ឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ កាលពីថ្ងៃទី០៨-៤-២០១១ តាមបញ្ញត្តិមាត្រា១០០នៃច្បាប់ស្តីពីព្រៃឈើ ។

២.ផ្តន្ទាទោស៖

ក-ឈ្មោះ [redacted]គា ហៅ[redacted] សាព៉ា ភេទប្រុស អាយុ៤៨ឆ្នាំ សញ្ជាតិខ្មែរ ដែលមានសាវតាជាតិដូចខាងលើ ដាក់ពន្ធនាគារកំណត់៥(ប្រាំឆ្នាំ) និងពិន័យជាប្រាក់៦៤,៩៥៨,៤៨០៛(ហុកសិបបួនលានប្រាំបួនសែនប្រាំម៉ឺនប្រាំបីពាន់បួនរយប៉ែតសិបរៀលគត់)។

គឺជាទោសរួមពីបទ គំរាមកំហែង រាំងស្ទះដល់ការបំពេញភារកិច្ច និង កិច្ចប្រតិបត្តិការរបស់មន្ត្រីរដ្ឋបាលព្រៃឈើ បទកាន់កាប់អាវុធដោយគ្មានលិខិអនុញ្ញាត បទធ្វើសន្និធិផល អនុផលព្រៃឈើ និងបទប្រមូលផល អនុផលព្រៃឈើដោយគ្មានលិខិតអនុញ្ញាត ប្រព្រឹត្តនៅភូមិសំបូរ ឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ កាលពីថ្ងៃទី០៨-៤-២០១១ តាមបញ្ញត្តិមាត្រា៤៩០, មាត្រា១៣៦ និងមាត្រា១៣៧ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា, មាត្រា១០០, មាត្រា៩៦-១-៣ និងតាមមាត្រា៩៨-២-៥ នៃច្បាប់ស្តីពីព្រៃឈើ ។

ខ-ឈ្មោះ [redacted]រិទ្ធិ ភេទប្រុស អាយុ២៨ឆ្នាំ សញ្ជាតិខ្មែរ ដែលមានសាវតាជាតិដូចខាងលើ ដាក់ពន្ធនាគារកំណត់២(ពីរឆ្នាំ) តែទោសនេះត្រូវអនុវត្តក្នុងពន្ធនាគារកំណត់ស្មើនឹងចំនួនថ្ងៃ ដែលជនជាប់ចោទត្រូវបានឃុំខ្លួនជាបណ្តោះអាសន្នទោសសល់ពីនេះត្រូវព្យួរ និង ពិន័យជាប្រាក់ ចំនួន១០,០០០,០០០៛(ដប់លានរៀល)។

ពីបទ ប្រមូលផល អនុផលព្រៃឈើ ដោយគ្មានលិខិតអនុញ្ញាត ប្រព្រឹត្តនៅភូមិសំបូរ ឃុំស្វាយជ្រះ ស្រុកស្នួល ខេត្តក្រចេះ កាលពីថ្ងៃទី០៨-៤-២០១១ តាមបញ្ញត្តិមាត្រា៩៨-២-៥ នៃច្បាប់ស្តីពីព្រៃឈើ និងមាត្រា១០៦ មាត្រា១០៧ មាត្រា១០៨ នៃក្រមព្រហ្មទណ្ឌព្រះរាជាណាចក្រកម្ពុជា។

៣.ឈ្មោះវត្ថុចាប់យកមានៈ

ក-ឈើគ្រាក់គ្រញូង ចំនួន២០៧៣ដុំ ស្មើនឹង១៨៣៦០គីឡូក្រាម ស្មើនឹង១១,០៨៦ម៉ែត្រគ្រីគុណ ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

ខ-រថយន្ត ម៉ាក ឡង់គ្រីស័រ(Landcruiser) ពណ៌ស្លែ ពាក់ស្លាកលេខ រាជការ៣៧៦០ ចំនួន ០១(មួយគ្រឿង) ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

គ-រថយន្ត ម៉ាក ឡិចស៊ីស(Lexus) ពណ៌ស្លែ គ្មានស្លាកលេខ ចំនួន០១(មួយគ្រឿង) ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

ឃ-រថយន្ត ម៉ាក តូពិច(Topic) ពណ៌ស្លាទុំ ផលិតឆ្នាំ១៩៩៣ លេខតួPK010605 គ្មានផ្លាកលេខសំគាល់ ចំនួន០១(មួយគ្រឿង) ត្រូវរឹបអូសជាសម្បត្តិរដ្ឋ ។

ង-រថយន្តម៉ាកតូយ៉ូតាកាមរី(Toyotacamry) ប្រភេទទេសចរណ៍ ពណ៌ប្រផេះ សេរីឆ្នាំ១៩៩៧ មានលេខតួJT2BG22K0V0036401 លេខម៉ាស៊ីន Nil ផ្លាកលេខ ភ្នំពេញ ២Q-០៦២៩ ត្រូវបប្រគល់ឲ្យម្ចាស់ដើមវិញ។

ច-ប្រាក់រៀលប្រភេទ៥០០០រចំនួន១០០(មួយរយសន្លឹក) ស្មើនឹង៥០០,០០០រ(ប្រាំសែនរៀល) ត្រូវប្រគល់ឲ្យម្ចាស់ដើមវិញ ។

ឆ-កាបូបលុយចំនួនមួយ និងទូរសព្ទ័ម៉ាកណូគា(Nokia) ពណ៌ខ្មៅ ចំនួនមួយ ត្រូវប្រគល់ឲ្យម្ចាស់ដើមវិញ ។

ជ-លិខិតបញ្ជាបេសកកម្ម មេបញ្ជាការដ្ឋានអង្គរក្ស ចំនួន០២ច្បាប់ ត្រូវប្រគល់ឲ្យម្ចាស់ដើមវិញ ។

ឈ-អាវុធប្រភេទអាកាស្វាយបត់ មានលេខ២២៦៦៥ ចំនួនពីរច្បាប់ ត្រូវប្រគល់ឲ្យម្ចាស់ដើមវិញ ។

ញ-សំបកគ្រាប់អាកា ចំនួនបីគ្រាប់ ត្រូវរឹបអូសបំផ្លាញចោល។ តាមបញ្ញត្តិមាត្រា៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈថ្ងៃទី២៥-កក្កដា-២០១២ ចំពោះមុខជនជាប់ចោទឈ្មោះ ថៃ គា មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទលោក[redacted]អ៊ាម កំបាំងមុខជនជាប់ចោទ[redacted]រិទ្ធិ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៧-៩-២០១២ចំពោះមុខជនជាប់ចោទឈ្មោះ ថៃ គា មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទលោក[redacted]អ៊ាម កំបាំងមុខជនជាប់ចោទ [redacted] រិទ្ធិ បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ៕

-បានឃើញរបាយការណ៍សំណុំរឿងព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ចុះថ្ងៃទី១០-៧-២០១៣ ។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ចុះថ្ងៃទី១៣-៨-២០១៣។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ[redacted]គា (វត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted]រិទ្ធិ (អវត្តមាន)

-មេធាវី [redacted] ម៉ាច (វត្តមាន)

-ជនជាប់ចោទឈ្មោះ [redacted] គា បានឆ្លើយថា: រឿងនេះខ្លួនអត់បានប្តឹងឧទ្ធរណ៍ទេ។ នៅពេលនេះខ្លួន សុំបញ្ជាក់ថា ខ្លួនអត់ បានប្រព្រឹត្តដូចកាចោទប្រកាន់ទាំងស្រុងទេ ខ្លួនអត់បានភ្ជុងកាំភ្លើងលើសមត្ថកិច្ច រឺ ជនណាទេ តែខ្លួនបានបាញ់ ឡើងលើប្រាកដមែន ដោយហេតុថាខ្លួនភ័យ នៅពេលគេចង់ចាប់ខ្លួនអត់ដីកាពីតុលាការ ខ្លួនអត់ដឹងថាជាអ្នកណា។ ខ្លួនមានកាំភ្លើង២ដើមប្រាកដមែន។ ខ្លួនជិះដេញតាមរថយន្តមែន តែអត់បានទៅសំឡុតអ្នកណាទេគឺទៅដើម្បីសម្រួលប៉ុណ្ណោះ។នៅពេលនេះខ្លួនសំណូមពរសុំបន្ធូរបន្ថយទោសឲ្យខ្លួនតាមច្បាប់។

**តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា**

រឿងនេះការសម្រេចរបស់សាលាដំបូងមានលក្ខណៈត្រឹមត្រូវហើយ ដូចនេះសុំលោកចៅក្រមពិចារណាសម្រេចតាមច្បាប់ចុះ ។

-មេធាវី [redacted] ម៉ាច បានធ្វើសេចក្តីសន្និដ្ឋានថា: កូនក្តីខ្លួនអត់បានប្រព្រឹត្ត ដូចការចោទប្រកាន់ទាំងស្រុងទេ។ កូនក្តីខ្លួនអត់មានចេតនាបាញ់លើជនរងគ្រោះណាមួយឡើយ។ ចំពោះបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញារង វាពុំត្រឹមត្រូវដោយហេតុថាព្រះរាជអាជ្ញាអត់បានផ្ទេរសិទ្ធិឲ្យប្តឹងទេ។ នៅពេលនេះខ្លួនសំណូមពរសុំតម្កល់សាលក្រមរបស់សាលាដំបូងដដែល ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

-ក្រោយពីបានពិនិត្យគ្រប់ឯកសារដែលពាក់ព័ន្ធ

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## <u>សាលាឧទ្ធរណ៍</u>

## <u>យល់ឃើញថា</u>

១-បណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី០១-១០-២០១២ របស់ឈ្មោះ [redacted] (អយ្យការ) ធ្វើឡើងក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះបានយោងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

២-ជនជាប់ចោទឈ្មោះ [redacted] គា បានឆ្លើយសារភាព: នៅថ្ងៃកើតហេតុ ដោយឃើញសមត្ថកិច្ចមកព័ទ្ធផ្ទះរបស់ខ្លួន ដោយពុំមានដីកា ពេលនោះខ្លួនបានឡើងទៅលើផ្ទះយកអាវុធបាញ់ឡើងទៅលើ ដោយពុំមានបំណងបាញ់សម្លាប់អ្នកណានោះទេ។ ខ្លួនពុំបានភ្ជង់សមត្ថកិច្ច ឬក៏បាញ់ទៅលើសមត្ថកិច្ចទេ។ កាំភ្លើងរបស់ខ្លួនមានAK មួយដើម និងK59មួយដើម មានលិខិតប្រើប្រាស់ ប៉ុន្តែហួសកំណត់ប្រើហើយ ។

៣-តាមអំណាចចម្លើយជនរងគ្រោះ និង ជាសមត្ថកិច្ច បានបញ្ជាក់ប្រហាក់ប្រហែលនឹងជនជាប់ចោទដែរ ប៉ុន្តែបានបន្ថែមថា ជនជាប់ចោទពិតជាបានភ្ជង់មកលើពួកខ្លួនប្រាកដមែន ។

៤-ទោះបីជាអង្គហេតុបង្ហាញឲ្យឃើញថាមានការភ្ជង់ទៅលើសមត្ថកិច្ចក៏ដោយ ក៏ជនជាប់ចោទពុំបានបាញ់ទៅលើជនរងគ្រោះទេ ហើយក៏ពុំមានអំពើប៉ុនប៉ងដែរ ដោយហេតុថាជនជាប់ចោទបញ្ឈប់សកម្មភាព ដោយឆន្ទៈរបស់ខ្លួន ។

៥-តំណាងមហាអយ្យការ បានធ្វើសេចក្តីសន្និដ្ឋានថា: រឿងនេះការសម្រេចរបស់សាលាដំបូងមានលក្ខណៈត្រឹមត្រូវហើយ ដូចនេះសុំលោកចៅក្រមពិចារណាសម្រេចតាមច្បាប់ចុះ ។

៦-មេធាវីការពារឲ្យជនជាប់ចោទបានធ្វើសេចក្ដីសន្និដ្ឋានថាៈ កូនក្ដីខ្លួនអត់បានប្រព្រឹត្ត ដូចការចោទប្រកាន់ទាំងស្រុងទេ។ កូនក្ដីខ្លួនអត់មានចេតនាបាញ់លើជនរងគ្រោះណាមួយឡើយ។ ចំពោះបណ្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញារង វាពុំត្រឹមត្រូវដោយហេតុថាព្រះរាជអាជ្ញាអត់បានផ្ទេរសិទ្ធិឲ្យប្ដឹងទេ។ នៅពេលនេះខ្លួន សំណូមពរ សុំតម្កល់សាលក្រមរបស់សាលាដំបូងដដែល ។

៧-ចំពោះចំណុចប្រគល់រថយន្តកាមរី ឲ្យម្ចាស់ដើមវិញ ឃើញថាការសម្រេចនេះត្រឹមត្រូវហើយ ដោយហេតុថាជារថយន្ត ដែលជាកម្មសិទ្ធិរបស់ឈ្មោះ យុន យឹម ដែលបានជូលឲ្យជនជាប់ចោទ ។

៨-រឿងក្ដីនេះ ត្រូវបានសាលាដំបូងខេត្តក្រចេះ ធ្វើការអង្កេតនឹងលើកយក សំអាងហេតុមកបញ្ជាក់ត្រឹមត្រូវតាមច្បាប់ហើយ សាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនោះ ដូចនេះសាលាឧទ្ធរណ៍មិនចាំបាច់លើកយកសំអាងហេតុនេះមកបញ្ជាក់ជាថ្មីទៀតទេ ។

៩-សាលក្រមព្រហ្មទណ្ឌលេខៈ ២៣"ច" ចុះថ្ងៃទី១៧-៩-២០១២ របស់សាលាដំបូងខេត្តក្រចេះ សម្រេចមានលក្ខណៈត្រឹមត្រូវតាមអង្គហេតុនឹងគតិច្បាប់ហើយគប្បីដំកល់ទុកជាបានការតទៅ ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្ដី

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០១-១០-២០១២ របស់ឈ្មោះ [redacted] ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនិងគតិច្បាប់ ។

២-តំកល់សាលក្រមព្រហ្មទណ្ឌលេខៈ២៣"ច"ចុះថ្ងៃទី១៧-៩-២០១២ របស់សាលាដំបូងខេត្តក្រចេះ ទុកជាបានការពេញទាំងមូល ។

៣-បន្តការឃុំខ្លួនលើជនជាប់ចោទឈ្មោះ [redacted] គា ។

៤-សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី២៩-៨-២០១៣ ចំពោះមុខជនជាប់ចោទ ទុកសិទ្ធិឲ្យប្ដឹងសាទុក្ខតាមកំណត់ច្បាប់ ។

**សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា ស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ គ្រប់តំណែង និង កងកំលាំងប្រដាប់អាវុធ ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច ប្រសិនបើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
| --- | --- | --- |
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ភ្នំពេញ, ថ្ងៃទី០៤ ខែ[illegible] ឆ្នាំ២០១៣

**ក្រឡាបញ្ជី**

**ម៉ម . [illegible]**

បានឃើញ

**ប្រធានសាលាឧទ្ធរណ៍**

[illegible]